**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ: ...៤៩១...... PC.អក

# សេចក្តីជូនដំណឹង
## ស្តីពី

ការពន្យារពេលក្នុងការដេញថ្លៃលក់ចលនទ្រព្យ និងអចលនទ្រព្យចាស់ៗ ខូចគុណភាព និងហួសសម័យកាលប្រើប្រាស់ចំនួន 847 មុខ របស់អគ្គិសនីកម្ពុជា.

**យោង** : លិខិតលេខ : ៣៤១ PC.អក ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០២២ របស់គណៈកម្មាធិការលទ្ធកម្មអគ្គិសនីកម្ពុជា
- លិខិតលេខ : ៤០១១ PC.អក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០២១ របស់គណៈកម្មាធិការលទ្ធកម្មអគ្គិសនីកម្ពុជា។

អគ្គិសនីកម្ពុជា សូមជូនដំណឹងដល់សាធារណៈជនដែលបានទិញឯកសារដេញថ្លៃក្នុងការលក់ចលនទ្រព្យ និងអចលនទ្រព្យចាស់ៗ ខូចគុណភាព និងហួសសម័យកាលប្រើប្រាស់ចំនួន 847 មុខ របស់អគ្គិសនីកម្ពុជាឲ្យបានជ្រាបថា ៖ តាមការគ្រោងទុក ការដេញថ្លៃក្នុងគម្រោងនេះនិងត្រូវធ្វើនៅវេលា ម៉ោង ០៩:០០ ព្រឹក ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០២២ ប៉ុន្តែដោយមានការឆ្លងរីករាលដាលនៃមេរោគកូវីដបំប្លែងថ្មី(អូមីក្រុង)ក្នុងរាជធានីភ្នំពេញ អគ្គិសនីកម្ពុជា សម្រេចធ្វើការដេញថ្លៃតាមរយៈប្រព័ន្ធបច្ចេកវិទ្យា Online (Zoom Meeting) និងពន្យារពេលការដេញថ្លៃនេះ ដើម្បីឲ្យអ្នកមានបំណងចង់ចូលរួមដេញថ្លៃបានសិក្សាស្វែងយល់ពីការដេញថ្លៃតាមរយៈប្រព័ន្ធបច្ចេកវិទ្យា Online (Zoom Meeting) និងសូមរក្សាការទទួលសំណើដេញថ្លៃ រហូតដល់វេលាម៉ោង ១៧:០០ ល្ងាច ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២២ ហើយការដេញថ្លៃនិងប្រព្រឹត្តទៅនៅវេលា ម៉ោង ០៩:០០ ព្រឹក ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២២ ។

សូមជូនភ្ជាប់ជាមួយនូវបែបបទនៃការបើកឯកសារដេញថ្លៃតាមរយៈប្រព័ន្ធបច្ចេកវិទ្យា Online (Zoom Meeting) ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រី ជ្រាបជាព័ត៌មាន ដោយអនុគ្រោះ ។

ថ្ងៃ ... ខែ មាឃ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០២២
**ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហាក់_ទូច**

**ចម្លងជូន៖**
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ